ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងព័ត៌មាន**

លេខ៖ ...១៤៩...សរណ ព.ម.

ថ្ងៃ.ពុធ.២.កើត...ខែ.បឋមាសាឍ ឆ្នាំ.មមី...អដ្ឋស័ក.ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី..១..... ខែ...កក្កដា ឆ្នាំ២០២៦.

## សូមជម្រាបជូន

## ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ម្ចាស់អង្គភាពប្រកបអាជីវកម្មពាក់ព័ន្ធនឹងវិស័យព័ត៌មាន និងសោតទស្សន៍

**កម្មវត្ថុ៖** ការចុះបញ្ជីប្រកបអាជីវកម្មក្នុងវិស័យព័ត៌មាន និងសោតទស្សន៍។

**យោង៖**
- អនុក្រឹត្យលេខ២១៧អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- ប្រកាសរួមលេខ១០០៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងព័ត៌មាន របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្ដីជូនដំណឹងលេខ៤៥១ ព.ម ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ក្រសួងព័ត៌មាន។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ជ្រាបថា កន្លងមក ក្រសួងព័ត៌មានបានសង្កេតឃើញអង្គភាពអាជីវកម្មពាក់ព័ន្ធនឹងវិស័យព័ត៌មាននិងសោតទស្សន៍មួយចំនួន បាននិងកំពុងធ្វើអាជីវកម្មដោយមិនមានអាជ្ញាបណ្ណ ដែលធ្វើឱ្យប៉ះពាល់សណ្ដាប់ធ្នាប់ និងការប្រកួតប្រជែងមិនស្មោះត្រង់។ ក្រសួងសូមបញ្ជាក់ថា ការប្រកបអាជីវកម្មកាសែត ព្រឹត្តិបត្រ ទស្សនាវដ្ដី គេហទំព័រ វិទ្យុ ទូរទស្សន៍ រោងពុម្ព គ្រឹះស្ថានបោះពុម្ពផ្សាយ សេវាបោះពុម្ព ភ្នាក់ងារផ្សាយពាណិជ្ជកម្ម និងសេវាផ្សព្វផ្សាយពាណិជ្ជកម្ម ត្រូវតែមានការអនុញ្ញាតពីក្រសួងព័ត៌មាន ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងស្របតាមច្បាប់ជាធរមាន។

ក្នុងន័យនេះ ក្រសួងព័ត៌មាន សូមធ្វើការណែនាំដល់ម្ចាស់អង្គភាពអាជីវកម្ម និងអ្នកពាក់ព័ន្ធ សូមមកបំពេញសំណុំបែបបទស្នើសុំធ្វើអាជីវកម្មនៅច្រកចេញ ចូលតែមួយរបស់ក្រសួងព័ត៌មាន ពីថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ រៀងរាល់ម៉ោងធ្វើការ (ឬតាមទំនាក់ទំនងទូរសព្ទលេខ ០៨៧ ៧៨០ ១៧៧) ចាប់ពីថ្ងៃជូនដំណឹងនេះតទៅរហូតដល់ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៦ ជាកំហិត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់អង្គភាពប្រកបអាជីវកម្មពាក់ព័ន្ធនឹងវិស័យព័ត៌មាន និងសោតទស្សន៍អនុវត្តតាមការណែនាំ និងចូលរួមសហការឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ទទួលនូវការរាប់អានពីខ្ញុំ។

**រដ្ឋមន្ត្រី**

**នេត្រ ភក្ត្រា**

**ចម្លងជូន៖ ៧**
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានពន្ធដារ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរព័ត៌មានរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ